# ខ្លឹមសារសង្ខេប

*KWAI CHOI v. Metali*, High Court, No. 175 of 1990, Judgement 12 September 1992

**ពាក្យគន្លឹះ÷** ការទទួលខុសត្រូវរបស់មន្ត្រីរាជការ អំពើអនីត្យានុកូលភាព និងសំណង

## ១. អង្គហេតុនិងនីតិវិធី

មន្ត្រីប៉ូលីសបានឃាត់ខ្លួនជនល្មើសដែលខកខានមិនបានចូលខ្លួន តាមដីការបស់តុលាការ ក៏ប៉ុន្តែ មិនបាននាំទៅជួបចៅក្រមភ្លាមទេ ហើយបានឃុំខ្លួនរហូតដល់៥២ម៉ោងនៅស្ថានីយ៍ប៉ូលីស។ ជនរងគ្រោះ បានប្តឹងទារសំណង ដោយចោទថាការឃុំខ្លួននោះខុសច្បាប់។ ប៉ូលីសទទួលស្គាល់ថាគាត់បានឃាត់ខ្លួន និងបញ្ជូនទៅស្ថានីយ៍ប៉ូលីសតាមបញ្ជារបស់ថ្នាក់លើ ហើយសាកសួរយោបល់បន្តបន្ទាប់ តែគ្មានការឆ្លើយ តបជាការណែនាំទេ។

## ២. សំអាងហេតុនិងសេចក្តីសម្រេច

តុលាការជាន់ខ្ពស់ បានពិចារណាថា តើប៉ូលីសជាមន្ត្រីរបស់រដ្ឋ អាចទទួលខុសត្រូវដែរឬទេ? ស្តេច (crown) នៃប្រទេសប្រ៊ុយណេ មិនត្រូវបានដាក់ឲ្យទទួលខុសត្រូវទេ លើកលែងតែមានច្បាប់ចែងឲ្យ ទទួលខុសត្រូវ។ មកដល់ពេលនេះ មិនមានច្បាប់ចែងអនុញ្ញាតទេ។ តុលាការ បានពិនិត្យច្បាប់និងការ អនុវត្តប្រទេសអង់គ្លេស (កំមុនឡ) ដែលជាអាណានិគមលើប្រទេសប្រ៊ុយណេ។ ពេលមុន ស្តេចរបស់អង់ គ្លេស មិនត្រូវបានដាក់ឲ្យទទួលខុសត្រូវទេ ក៏ប៉ុន្តែ នាពេលនេះ ក្នុងករណីខ្លះ អាចត្រូវបានប្តឹងប្រឆាំង បាន។ តុលាការប្រទេសសឹង្ហបុរី ក៏អនុញ្ញាតឲ្យប្តឹង និងដាក់ឲ្យមានការទទួលខុសត្រូវផងដែរ។ ប្រសិនបើ មិនដូចនេះ វាមិនយុត្តិធម៌ទេ ខណៈដែលពេទ្យឯកជនមានកំហុស អាចត្រូវប្តឹងបាន តែពេទ្យរបស់រដ្ឋបែរ ជាមិនអាចត្រូវប្តឹងបាន។ ជាសរុប ការអនុវត្តនិងច្បាប់ អនុញ្ញាតឲ្យប្តឹងប្រឆាំងនឹងបុគ្គល ធ្វើការងារឲ្យរាជ ការ (មិនអាចប្តឹងរដ្ឋទេ)។ ការបកស្រាយផ្សេងពីនេះ (មិនឲ្យទទួលខុសត្រូវ) ជនរងគ្រោះនឹងមិនទទួល បានសំណងទេ។ អ្វីសំខាន់ គឺអាស្រ័យលើរដ្ឋ នៅពេលរកឃើញថាមន្ត្រីមានកំហុស រដ្ឋជាអ្នកសម្រេចថា រដ្ឋជាអ្នកចេញសំណង ឬប៉ូលីសចេញសំណងដោយខ្លួនឯង។

ប៉ូលីសបានដោះសារថា ដីកាមានខ្លឹមសារមិនច្បាស់។ ដូចនេះ ក្រោយឃាត់ខ្លួន គាត់មិនបាននាំ ជនសង្ស័យទៅជួបចៅក្រមភ្លាមទេ។ គាត់នាំទៅស្ថានីយ៍ប៉ូលីសតាមបញ្ជាថ្នាក់លើ។ ប៉ូលីស បានព្យាយាម

ទាក់ទងចៅក្រម និងថ្នាក់លើដើម្បីសុំការណែនាំបន្ត ក៏ប៉ុន្តែ មិនមានការឆ្លើយតប។ តុលាការអះអាងថា បញ្ជាថ្នាក់លើ មិនទទួលយកជាការដោះសារទេ។

ពាក់ព័ន្ធនឹងសំណង តុលាការពិចារណាឃើញថា មានការឃាត់ខ្លួន លើសរយៈពេលច្បាប់កំណត់ ។រូបភាពនៃការឃាត់ខ្លួន ត្រូវបានផ្សាយក្នុងទំព័រកាសែតផងដែរ។ នេះនាំឱ្យប៉ះពាល់ដល់កិត្តិយស។ ចៅក្រមមិនរកឃើញមានស្ថានទម្ងន់នៃទង្វើរបស់ប៉ូលីស និងមិនមានទង្វើ insulting ដោយប៉ូលីសទេ។ ការឃាត់នេះខុសច្បាប់ចំនួន៦ម៉ោង។ តុលាការពិនិត្យមើលយុត្តិសាស្ត្រកន្លងមកពាក់ព័ន្ធការផ្តល់សំណងនៃការឃាត់ខ្លួនខុសច្បាប់ ហើយសម្រេចឱ្យសងប៉ូលីសសងជនរងគ្រោះចំនួន៣០០០ ដុល្លាប្រ៊ុយណេ (២០០០ដុល្លាអាមេរិក)។

## ៣.ខ្លឹមសារដកស្រង់ឬយោបល់

*An warrant of arrest is a powerful expedient and must be strictly observed, as must the relevant provisions of the CPC.*

*It is not a defence to a claim by a plaintiff that he was acting in accordance with the instructions given to him by a superior.*

*"It was pointed out by Scott L.J. in Dumbell v Roberts that where a person has been wrongfully arrested and detained, it is in the public interest that sufficient damages should be awarded in order to give reality to the protection afforded by the law to personal freedom. Furthermore, as Lawrence L.J. observed in Walter v All tools Ltd., a false imprisonment does not merely affect a man's liberty ; it also affects his reputation".*

តាមវិធានសិទ្ធិមនុស្ស នៅពេលឃាត់ខ្លួន ជននោះត្រូវតែបានបញ្ជូនទៅបង្ហាញខ្លួននៅមុខចៅក្រមភ្លាម។ ខ្លឹមសារនៃសាលក្រមដូចដកស្រង់ខាងលើ បានបញ្ជាក់ថា បញ្ជាថ្នាក់លើ ដើម្បីដោះសារការឃឹតយ៉ាវ មិនត្រូវទទួលយកទេ។ ជនគ្រប់រូបត្រូវទទួលបានការការពារតាមផ្លូវច្បាប់ ទោះបីការបំពានដោយអាជ្ញាធររដ្ឋក្តី។ រដ្ឋមិនទទួលខុសត្រូវ តែមន្ត្រីអនុវត្តតួនាទីជាមន្ត្រីរដ្ឋ ត្រូវទទួលខុសត្រូវជាបុគ្គល តាមទម្រង់ការទទួលខុសត្រូវលើអំពើអនីត្យានុកូលភាព (tort)។ ទោះបីវាមិនមែនជាការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រឹមតែទទួលខុសត្រូវរដ្ឋប្បវេណីក្តី ក៏ប៉ុន្តែ នេះនឹងជួយជម្រុញឱ្យមន្ត្រីអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ។

## ៤.ឯកសារ

សម្រាប់សាលក្រមទាំងស្រុងសូមចូលទៅកាន់÷

Microsoft Word - KUAN KWAI CHOI V AK ZAIDI BIN PG METALI (measboralaws.com)